នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Apr-2021, 08:23
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំពន្យារពេលសវនាការបណ្ដឹងសាទុក្ខ ដែលគ្រោងធ្វើនៅថ្ងៃទី១៧ - ២១ ខែឧសភា ឆ្នាំ២០២១

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្ដី ខៀវ សំផន**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

**ចម្លើយតប**

1. តាមស្មារតីនៃស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា និងសវនាការលើបណ្តឹងសាទុក្ខដែលបច្ចុប្បន្ន គ្រោងនឹងធ្វើនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ពន្យារពេលសវនាការ("សំណើពន្យារពេល") យ៉ាងហោចណាស់រហូតដល់ខែកក្កដា ឆ្នាំ២០២១ ដើម្បីឱ្យទម្រង់ការនានាត្រូវបានរៀបចំឱ្យបានស្រេចបាច់ជាមុន ធ្វើយ៉ាងណាដើម្បីថែរក្សានូវតម្លៃសវនាការលើបណ្តឹងសាទុក្ខឱ្យបានល្អបំផុត ខណៈពេលជាមួយគ្នាក៏ដើម្បីការពារនូវសុខភាពរបស់អ្នកចូលរួម ឱ្យបានល្អបំផុតតាមដែលអាចធ្វើបានផងដែរ[1]។ សំណើពន្យារពេល បានកត់សម្គាល់ជាពិសេស ចំពោះសារសំខាន់នៃវត្តមានរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ និងសូមស្នើឱ្យមានការចាត់វិធានការផ្សេងៗដើម្បីជួយសម្រួលដើម្បីជាការទទួលស្គាល់ចំពោះឋានៈរបស់ពួកគេក្នុងនាមជាភាគីនៃកិច្ចដំណើរការនីតិវិធី។

2. សហព្រះរាជអាជ្ញាសូមបង្រួមតាមរយៈសេចក្តីយោងនូវប្រវត្តិនីតិវិធី និងច្បាប់ជាធរមានដែលបានចែងនៅក្នុងសំណើពន្យារពេល[2]។

3. សហព្រះរាជអាជ្ញាកត់សម្គាល់ថា សំណើពន្យារពេលនេះ លើកឡើងនូវបញ្ហាពាក់ព័ន្ធដែលត្រូវដោះស្រាយឱ្យបានដាច់ស្រេច មុនពេលស្តាប់អំណះអំណាងផ្ទាល់មាត់ ជាពិសេស ដោយពិចារណាលើការរីតត្បិតពាក់ព័ន្ធនឹងបញ្ហាកូវីដ ១៩ (COVID-19) ថ្មីៗនេះ នៅក្នុងទីក្រុងភ្នំពេញ និងភាពមិនប្រាកដប្រជាជុំវិញដំណោះស្រាយរបស់វា ត្រឹមកាលបរិច្ឆេទនៃសវនាការដែលបានគ្រោងទុកនាពេលបច្ចុប្បន្ននេះ។ សហព្រះរាជអាជ្ញា ក៏បានកត់សម្គាល់នូវទស្សនៈរបស់សហមេធាវីនាំមុខដែលថា ទម្រង់មួយចំនួននៃការចូលរួមដោយផ្ទាល់ដោយភាគីទាំងអស់ មានសារសំខាន់សម្រាប់ទាំងគំនិតយល់ឃើញរបស់សាធារណជនចំពោះតុលាការ និងទាំងការចូលរួមបានល្អបំផុតនៅក្នុងកិច្ចដំណើរការនីតិវិធី[3]។

4. សហព្រះរាជអាជ្ញាយល់ឃើញថា សេចក្តីសម្រេចលើបញ្ហាទាំងអស់នេះស្ថិតនៅក្នុងឆន្ទានុសិទ្ធិត្រឹមត្រូវរបស់ អ.ជ.ត.ក និងមានទំនុកចិត្តថា អ.ជ.ត.ក នឹងដាក់ចេញនូវវិធានការចាំបាច់ ដើម្បីធ្វើឱ្យមាន

---

[1] ឯកសារ **F61** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យពន្យារពេលសវនាការបណ្តឹង សាទុក្ខ ដែលគ្រោងធ្វើឡើងនៅថ្ងៃទី១៧-២១ ខែឧសភា ឆ្នាំ២០២១ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ ("សំណើពន្យារពេល")។

[2] ឯកសារ **F61** សំណើពន្យារពេល កថាខណ្ឌ ៣-១៥ (ប្រវត្តិនីតិវិធី), ១៦-២១ (ច្បាប់ជាធរមាន)។

[3] ឯកសារ **F61** សំណើសុំពន្យារពេលវេលា កថាខណ្ឌ ២២-៦៥។

តុល្យភាពសិទ្ធិរបស់ភាគីទាំងអស់ក្នុងពេលសវនាការ ជាមួយនឹងសុវត្ថិភាពរបស់អ្នកចូលរួម។ សហព្រះរាជអាជ្ញាស្នើសុំឱ្យ អ.ជ.ត.ក សម្រេចលើបញ្ហានេះឱ្យបានឆាប់រហ័ស និងជូនដំណឹងដល់ភាគីឱ្យបានឆាប់តាមដែលអាចធ្វើបាន ទោះជាផ្លូវការ ឬក្រៅផ្លូវការ ដើម្បីឱ្យមានភាពច្បាស់លាស់ទាន់ពេលវេលា ក្នុងការរៀបចំកាលវិភាគសវនាការ និងអនុញ្ញាតឱ្យមានការធ្វើការសម្រេចចិត្តទាន់ពេល ទាក់ទងនឹងការរៀបចំការធ្វើដំណើររបស់អ្នកចូលរួមនៅក្រៅប្រទេសកម្ពុជា៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | [signature] |